# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ: ០៧៤/១៤ ស.ខ.ក.ក.

## សេចក្តីប្រកាសព័ត៌មាន

### ស្តីពី

### ឯកឧត្តម ថាច់ សេដ្ឋា មេដឹកនាំបាតុកម្ម បានដាក់ពាក្យបណ្តឹង ករណីគំរាមសម្លាប់លោក

សហគមន៍ខ្មែរកម្ពុជាក្រោម មានកិត្តិយសសូមទូលប្រគេនព្រះតេជព្រះគុណម្ចាស់ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ លោក លោកស្រី យុវជន បណ្តាញសារព័ត៌មាន និងបងប្អូនជនរួមជាតិថា ឯកឧត្តម ថាច់ សេដ្ឋា បានដាក់ពាក្យបណ្តឹងនៅក្រសួងមហាផ្ទៃ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤នេះ ពាក់ព័ន្ធជនមិនស្គាល់មុខបានទូរស័ព្ទទៅគំរាមសម្លាប់លោក ដោយបាននិយាយថា ឱ្យលោកឈប់ដឹកនាំធ្វើបាតុកម្មប្រឆាំងរដ្ឋាភិបាលវៀតណាមជាបន្តទៀត ប្រសិនបើមិនឈប់ទេ ទាហានវៀតណាមនឹងសម្លាប់លោក ព្រោះទាហានវៀតណាមនៅកម្ពុជាច្រើនណាស់សព្វថ្ងៃនេះ។ ប្រសិនបើនៅតែរឹងទទឹងទៅបាតុកម្មនៅខាងមុខស្ថានទូតវៀតណាម ប្រយ័ត្នស៊ីគ្រាប់បែក ហើយបាននិយាយថា គេធ្វើការនៅស្ថានទូតវៀតណាម ។

លោក ថាច់ សេដ្ឋា ស្នើសុំក្រសួងមហាផ្ទៃមេត្តាជួយស្រាវជ្រាវ និងចាត់វិធានការដ៏មានប្រសិទ្ធភាពទៅតាមនីតិវិធី ដើម្បីទប់ស្កាត់ និងរកមុខរកជនគំរាមសម្លាប់លោកមកផ្តន្ទាទោសតាមច្បាប់ ចៀសវាងកុំឲ្យមានការគំរាមកំហែងមកលើរូបលោក ក៏ដូចជាប្រជាពលរដ្ឋខ្មែរដទៃទៀត ជាបន្តទៀត។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែតុលា ព.ស.២៥៥៨ គ.ស.២០១៤

**សហគមន៍ខ្មែរកម្ពុជាក្រោម**

## PRESS RELEASE

HON. THACH SETHA, PROTEST LEADER, FORMALLY FILED A COMPLAINT ON DEATH THREAT WITH INTERIOR MINISTRY

KKC (The Khmer Kampuchea Krom Community) has an honor to inform you, the venerable Buddhist monks, media, compatriots and the public that Hon. Thach Setha, KKC president and former Senator, today has filed a formal complaint with the Ministry of Interior on death threat he received on October 6, 2014 from an anonymous person, who said to be working in the Embassy of Vietnam, to stop leading the demonstration to protect Khmer history against Vietnam for fabricating, falsifying Khmer history. If Mr. Thach Setha continued to lead the protest, he would be killed in a grenade attack as there are many Vietnamese soldiers in Cambodia.

Mr. Thach Setha requests MoI to take effective legal measure against the assailant to prevent any threats against him and other citizens from taking place again.

---